ក្រសួងអប់រំរដ្ឋ NSW

Understanding and using your body and mind

Family resources

# ការយល់ដឹង និងការប្រើប្រាស់រាងកាយ និងគំនិតរបស់អ្នក

## ធនធានសម្រាប់គ្រួសារ



ក្របខ័ណ្ឌការរៀនសូត្រសម្រាប់កុមារតូច (Early Years Learning Framework) គឺជាក្របខ័ណ្ឌជាតិលើការរៀនសូត្រ ដែលត្រូវបានប្រើនៅក្នុងមត្តេយ្យសាលា និងសេវាកម្មកុមារតូចទាំងអស់។ វាណែនាំការបង្រៀន និងការរៀនសូត្រដោយមានលទ្ធផលនៃការរៀនសូត្រចំនួនប្រាំ ដែលជួយឱ្យកុមារក្លាយជាអ្នករៀនពូកែ និងមានសមត្ថភាព។

លទ្ធផលនៃការរៀនសូត្រទី 3 គឺអំពីកុមារញ៉ាំបានល្អ មានសកម្មភាព និងមានអារម្មណ៍ល្អចំពោះខ្លួនឯង។ កុមារអភិវឌ្ឍការដឹងពីសុខុមាលភាពច្បាស់លាស់ ដោយបង្កើតទំនាក់ទំនងរឹងមាំ និងរៀនគ្រប់គ្រងអារម្មណ៍របស់ពួកគេ។ កុមាររៀនធ្វើការជ្រើសរើសចំណីអាហារដែលមានសុខភាពល្អ និងអភិវឌ្ឍជំនាញចលនាដើម្បីចូលរួមក្នុងសកម្មភាពរាងកាយ និងធំលូតលាស់រឹងមាំ ហើយមានសុខភាពល្អ។

សម្រាប់ព័ត៌មានបន្ថែមអំពី Early Years Learning Framework សូមចូលទៅមើល៖

https://www.education.gov.au/collections/translations-belonging-being-and-becoming-early-years-learning-framework-australia

### សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកមត្តេយ្យសាលា ឬសេវាកម្មសម្រាប់កុមារតូចរបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាផ្ទាល់មាត់ ដើម្បីជួយក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ ប្រតិបត្តិករនឹងហៅលេខទូរស័ព្ទដែលអ្នកផ្តល់ឱ្យ ហើយរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទជូនអ្នក ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។



NSW GOVERNMENT

# ការរៀនសូត្រនៅសាលារៀន

សិស្សមានអារម្មណ៍ជាប់ទាក់ទងគ្នា មានទំនាក់ទំនងវិជ្ជមាន និងត្រូវបានផ្តល់អំណាចដើម្បីធំលូតលាស់ និងទទួលជោគជ័យ (ផ្នែកមុខវិជ្ជាទាំងអស់)

សិស្សអភិវឌ្ឍសុខុមាលភាពខាងសង្គម អារម្មណ៍ និងរាងកាយតាមរយៈសិល្បៈ (មុខវិជ្ជា៖ សិល្បៈច្នៃប្រឌិត)

សិស្សអាចធ្វើការជ្រើសរើសដែលមានសុខភាពល្អ ដើម្បីថែរក្សារាងកាយរបស់ពួកគេ (មុខវិជ្ជា៖ ការអប់រំរាងកាយ)

សិស្សអាចថែរក្សា និងគោរពអ្នកដទៃ (មុខវិជ្ជា៖ ការអប់រំរាងកាយ)

## ការរៀនសូត្រសម្រាប់កុមារតូច

កុមារដឹងថាពួកគេអាចគ្រប់គ្រងអារម្មណ៍របស់ពួកគេ សហការជាមួយអ្នកដទៃ និងមានអារម្មណ៍សប្បាយរីករាយ

កុមារដឹងថាជម្រើសអាហារដែលមានសុខភាពល្អ ជួយឱ្យរាងកាយរបស់ពួកគេធំលូតលាស់ និងរឹងមាំ

កុមារអាចលេង និងរៀនជាមួយអ្នកដទៃ ហើយមានអារម្មណ៍ល្អចំពោះខ្លួនឯង

កុមារអាចបញ្ចេញមតិដោយខ្លួនឯងតាមរយៈកីឡា តន្ត្រី សិល្បៈដែលមើលឃើញ ចលនា និងរបាំ

## ការដឹងពីសុខុមាលភាពច្បាស់លាស់មានន័យថា៖